ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ៣៤ អនក្រ.បក

លេខ... ថ្ងៃទី... ខែ... ឆ្នាំ... ម៉ោង... នាទី

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុ តាមបំណងក៏ពីមានពិការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៩/អនក្រ/បក ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៩/អនក្រ/បក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០២

សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលបំណង ក្នុងការរៀបចំនីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុ ដោយធ្វើការផ្លាស់ប្តូរស្ថានភាពពីមន្ត្រីរាជការ ទៅជានិវត្តជន ជាពិសេសការផ្លាស់ប្តូរពីការទទួលបៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ទៅជាការទទួលប្រាក់សោធននិវត្តន៍ជំនួសវិញ ឱ្យបានទាន់ពេលវេលា ដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា។

មាត្រា ២.-

អនុក្រឹត្យនេះ មិនអនុវត្តចំពោះការដាក់ឱ្យចូលនិវត្តន៍តាមការស្នើសុំ ការចូលនិវត្តន៍ដោយបញ្ញត្តិ និងការចូលនិវត្តន៍ដោយសារការបាត់បង់សម្បទាវិជ្ជាជីវៈទេ។

## ជំពូកទី ២
## នីតិវិធីនៃការដាក់ឱ្យចូលនិវត្តន៍តាមអាយុ

មាត្រា ៣.-

មន្ត្រីរាជការស៊ីវិលទាំងពីរភេទ ត្រូវដាក់ឱ្យចូលនិវត្តន៍ជាកំហិតតាមអាយុ ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ របស់មន្ត្រីរាជការស៊ីវិលទាំងនោះ។

មាត្រា ៤.-

ជារៀងរាល់ឆ្នាំ គម្រោងផែនការស្ថិតិ និងថវិកា សម្រាប់មន្ត្រីរាជការស៊ីវិល ដែលចូលនិវត្តន៍តាមអាយុ ត្រូវរៀបចំដោយប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីជូនក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជូនលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំថវិកាសម្រាប់ឆ្នាំបន្ទាប់។ ចំពោះគម្រោងស្ថិតិ និងថវិកាសម្រាប់មន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ដោយការស្នើសុំ ដោយបញ្ញត្តិ និងដោយសារការបាត់បង់សម្បទាវិជ្ជាជីវៈ ជាភារកិច្ចរបស់សាមីក្រសួង ស្ថាប័ននីមួយៗ។

មាត្រា ៥.-

បញ្ជីរាយនាមមន្ត្រីរាជការស៊ីវិលដែលត្រូវចូលនិវត្តន៍នៅគ្រប់ក្រសួង ស្ថាប័នទាំងអស់ ត្រូវបានរៀបចំដោយប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានយ៉ាងតិច ១៨ ខែ មុនអាយុចូលនិវត្តន៍។ បញ្ជីនេះត្រូវចែកជូនដល់សាមីក្រសួង ក្រសួង

សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

មាត្រា ៦.-

ក្រសួង ស្ថាប័នសាមីទាំងអស់ ត្រូវត្រៀមរៀបចំដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ និវត្តន៍នេះ ទៅតាមបញ្ជីរាយនាមមន្ត្រីរាជការដែលខ្លួនគ្រប់គ្រងឱ្យបានមុន ៦ ខែ នៃការដល់អាយុចូលនិវត្តន៍ ។ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសស្តីពីការដាក់ឱ្យចូលនិវត្តន៍ត្រូវចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

មាត្រា ៧.-

ក្នុងករណីយឺតយ៉ាវ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវធ្វើការពិគ្រោះជាមួយសាមីក្រសួង ស្ថាប័នសាមី ហើយបើនៅតែមានការយឺតយ៉ាវទៀតនោះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវកាត់ឈ្មោះចេញពីតារាងបើកប្រាក់បៀវត្សរ៍ស្វ័យប្រវត្តិ ហើយសាមីក្រសួង ស្ថាប័នត្រូវទទួលខុសត្រូវទាំងស្រុងចំពោះវិបាកនៃការដាក់មន្ត្រីរាជការស៊ីវិលរបស់ខ្លួនឱ្យចូលនិវត្តន៍ ។

## ជំពូកទី ៣

## អន្តរប្បញ្ញត្តិ

មាត្រា ៨.-

ចំពោះមន្ត្រីរាជការស៊ីវិលដែលមានអាយុត្រូវចូលនិវត្តន៍ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមានរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ការដាក់ឱ្យចូលនិវត្តន៍ត្រូវធ្វើដោយរំលង។

មាត្រា ៩.-

ចំពោះបញ្ជីរាយនាមមន្ត្រីរាជការស៊ីវិលទាំងអស់ដែលមានអាយុចូលនិវត្តន៍នៅឆ្នាំ ២០០៣ ត្រូវរៀបចំរួចដោយប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានមុនដំណាច់ខែ សីហា ឆ្នាំ ២០០២។

មាត្រា ១០.-

ចំពោះមន្ត្រីរាជការស៊ីវិលដែលមានអាយុត្រូវចូលនិវត្តន៍ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០៣ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៣ ការរៀបចំដាក់ឱ្យចូលនិវត្តន៍ត្រូវធ្វើឱ្យបានមុនថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០២។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១២

-គ្រប់ក្រសួង ស្ថាប័ន

-ឯកសារ-កាលប្បវត្តិ